# សេចក្តីថ្លែងការណ៍ព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា សាស្ត្រាចារ្យ សូរិយា ស៊ូប៊ែឌី

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤

ខ្ញុំជិតនឹងបញ្ចប់បេសកកម្មស្វែងរកការពិតផ្នែកសិទ្ធិមនុស្សលើកទីដប់របស់ខ្ញុំនៅព្រះរាជាណាចក្រកម្ពុជា ហើយវាជាបេសកកម្មលើកទីមួយចាប់តាំងពីមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងខែកក្កដា ឆ្នាំ២០១៣។ អ្វីដែលខ្ញុំស្នើសុំបញ្ជាក់នោះ គឺជាការរកឃើញ និង ការយល់ឃើញលើកដំបូងរបស់ខ្ញុំអំពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ចាប់តាំងពីបេសកកម្មលើកចុងក្រោយរបស់ខ្ញុំ។ សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់ខ្ញុំនឹងដាក់ចូលក្នុងរបាយការណ៍របស់ខ្ញុំដែលនឹងដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅខែកញ្ញា ឆ្នាំនេះ។

ក្នុងអំឡុងពេលបេសកកម្មរបស់ខ្ញុំលើកនេះ ខ្ញុំបានជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយមានការចូលរួមរបស់ឧបនាយករដ្ឋមន្ត្រី លោក សុខ អាន និង លោក ហោ ណាំហុង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការសិទ្ធិមនុស្សកម្ពុជា លោក ឪម យិនទៀង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក អង្គ វង្សវឌ្ឍានា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោក ព្រុំ សុខា និង អភិបាលរាជធានីភ្នំពេញ លោក ប៉ា សុជាតិវង្ស។ ដូចគ្នានឹងបេសកកម្មលើកមុនៗរបស់ខ្ញុំដែរ ខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ក្នុងនោះមានប្រជាពលរដ្ឋសាមញ្ញ ក្រុមយុវជន និងនិស្សិត អង្គការសង្គមស៊ីវិល មេដឹកនាំគណបក្សប្រឆាំង ក៏ដូចជាសមាជិកនៃសហគមន៍អន្តរជាតិរួមទាំងដៃគូអភិវឌ្ឍ និងក្រុមស្ថាប័នអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ ខ្ញុំក៏បានជួបជាមួយសាច់ញាតិ និង មេធាវីមួយចំនួនរបស់អ្នកទាំង២៣នាក់ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២ និង ៣ ខែ មករា។

ជាដំបូង ខ្ញុំសូមអរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់កិច្ចសហការជាវិជ្ជមាន និង ក្នុងន័យស្វាគមន៍ជាមួយខ្ញុំ ក្នុងអំឡុងពេលបេសកកម្មលើកនេះ។ កិច្ចពិភាក្សារបស់ខ្ញុំជាមួយលោកនាយករដ្ឋមន្ត្រីមានភាពស្មោះត្រង់ ស្និទ្ធស្នាលរាក់ទាក់ និង ផ្តល់ព័ត៌មាន។ ដូចខ្ញុំបានបញ្ជាក់កន្លងមក នៅក្នុងការបំពេញអាណត្តិរបស់ខ្ញុំជាអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សប្រចាំកម្ពុជាដែលក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានប្រគល់ភារកិច្ចមកឲ្យនោះ វាមានសារៈសំខាន់ណាស់ដែលខ្ញុំមានលទ្ធភាពធ្វើការពិភាក្សាដ៏មានអត្ថន័យជាមួយតួអង្គទាំងអស់នៅក្នុងសង្គមកម្ពុជា ជាពិសេសជាមួយរាជរដ្ឋាភិបាល។

ដោយផ្តល់កិច្ចសហការពេញលេញជាមួយខ្ញុំ ក្នុងអំឡុងដំណើរទស្សនកិច្ចលើកនេះ និង ផ្តល់កិច្ចពិភាក្សាដ៏មានអត្ថន័យនោះ លោកនាយករដ្ឋមន្ត្រីបានបញ្ជូនសញ្ញាដ៏មានសារៈសំខាន់មួយទៅកាន់សហគមន៍អន្តរជាតិថា លោកត្រៀមខ្លួនជាស្រេច និង មានឆន្ទៈដោះស្រាយបញ្ហាសិទ្ធិមនុស្សនៅប្រទេសកម្ពុជាយ៉ាងហ្មត់ចត់។

រហូតដល់ចុងឆ្នាំ ២០១៣ ការវាយតម្លៃរបស់ខ្ញុំអំពីការវិវត្តន៍នៃស្ថានការណ៍សិទ្ធិមនុស្ស ជាទូទៅឃើញថាមានលក្ខណៈវិជ្ជមាន។ នៅក្នុងបេសកកម្ម និង នៅក្នុងរបាយការណ៍លើកមុនៗរបស់ខ្ញុំ ខ្ញុំបានអំពាវនាវឲ្យរដ្ឋាភិបាលបង្កលក្ខណៈឲ្យប្រធានគណបក្សប្រឆាំង លោក សម រង្ស៊ី បានវិលត្រឡប់មកកាន់ប្រទេសវិញ បន្ទាប់ពីមានការជន្លៀសខ្លួន និង បានចូលរួមធ្វើនយោបាយដោយសកម្មនៅក្នុងប្រទេស។ ខ្ញុំមានការរីករាយនៅពេលលោក សម រង្ស៊ី ទទួលការលើកលែងទោសពីព្រះមហាក្សត្រទាន់ពេលវេលា ដើម្បីដឹកនាំគណបក្សរបស់លោកនៅក្នុងការបោះឆ្នោតនៅខែកក្កដា។ ខ្ញុំបានកត់សំគាល់ថា ការបោះឆ្នោតបានប្រព្រឹត្តឡើងដោយសន្តិវិធីជាច្រើន ប៉ុន្តែវាមានភាពសៅហ្មងដោយមានការចោទប្រកាន់អំពីភាពមិនប្រក្រតីនៃការបោះឆ្នោត។ ដោយអំពាវនាវឲ្យមានការស៊ើបអង្កេតការចោទប្រកាន់ទាំងនេះដោយឯករាជ្យ និង ជឿទុកចិត្តបាននោះ គណបក្សសង្គ្រោះជាតិបានបដិសេធមិនចូលសភា។ ប៉ុន្តែ ខ្ញុំបានកត់សំគាល់ដោយពេញចិត្តថា ក្រោយការបោះឆ្នោត ភាគច្រើន ប្រជាពលរដ្ឋអាចសំដែងមតិដោយសេរី និង ទទួលបានសេរីភាពក្នុងការជួបជុំដោយធ្វើការដង្ហែរក្បួនតវ៉ា និង បាតុកម្មជាច្រើន ទាំងក្នុងទ្រង់ទ្រាយធំ និងទ្រង់ទ្រាយតូច។ ការដង្ហែរក្បួនតវ៉ា និងបាតុកម្មទាំងនេះ បានប្រព្រឹត្តទៅដោយមានវិន័យល្អ និង ប្រកបដោយសន្តិវិធី ហើយជាទូទៅពុំទទួលបានការរិតត្បិតពីអាជ្ញាធរឡើយ។ ខ្ញុំមានជំនឿថា លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តសិទ្ធិ និង សេរីភាពរបស់គេ គឺជាសញ្ញាមួយបង្ហាញពីលទ្ធិប្រជាធិបតេយ្យចាស់ទុំនៅក្នុងប្រទេសកម្ពុជា ដែលករណីនេះខ្ញុំស្វាគមន៍។ ប៉ុន្តែ អំពើហិង្សា និង ការប្រើប្រាស់កម្លាំងជ្រុលហួសហេតុកាលពីថ្ងៃទី ១៥ និង ២២ ខែ កញ្ញា និង ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ហើយ ថ្មីៗនេះ នៅថ្ងៃទី ២ ថ្ងៃទី ៣ និង ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១៤ បានចោទជាចម្ងល់លើទិដ្ឋភាពនេះ។ ទន្ទឹមនឹងខ្ញុំធ្វើការថ្កោលទោសផងដែរពីអំពើហិង្សាដែលប្រព្រឹត្តដោយបាតុករមួយ ចំនួននោះ វិធានការរបស់អាជ្ញាធរក្នុងការបង្ក្រាបលើហ្វូងមនុស្សនៅក្នុងសប្តាហ៍ទីមួយនៃខែមករា បង្ហាញឲ្យឃើញពីការផ្លាស់ប្តូរគួរឲ្យបារម្ភពីការឆ្លើយតបដោយអធ្យាស្រ័យ ទៅជាការឆ្លើយតបដោយការបង្ក្រាបរបស់រដ្ឋាភិបាលទៅលើការតវ៉ាជាសាធារណៈ ដែលការឆ្លើយតបដោយបង្ក្រាបនេះបានទទួលការថ្កោលទោសជាអន្តរជាតិ។

នេះជាការងារដែលខ្ញុំបានធ្លាប់បំពេញបេសកកម្មរបស់ខ្ញុំ។

**ការប្រើប្រាស់កម្លាំងជ្រុលហួសហេតុពីថ្ងៃទី ២ ដល់ ថ្ងៃទី ៤ ខែ មករា**

ខ្ញុំមានការព្រួយបារម្ភជាខ្លាំងពីទង្វើរបស់អាជ្ញាធរទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសប្តាហ៍ទីមួយនៃខែមករា។ ចំពោះការព្រួយបារម្ភនេះ ខ្ញុំសូមជំរុញឲ្យអាជ្ញាធរស្វែងរកការដោះលែងជាបណ្តោះអាសន្នចំពោះអ្នកទាំង២៣នាក់ដែលត្រូវបានចាប់ខ្លួន ជាពិសេស អ្នកដែលត្រូវការទទួលការព្យាបាលជាបន្ទាន់នោះ។ ដោយរង់ចាំការដោះលែងនោះ ខ្ញុំសូមជំរុញឲ្យមានការផ្លាស់អ្នកជាប់ឃុំទាំងនោះមកកាន់មណ្ឌលឃុំខ្លួនបណ្តោះអាសន្នសមស្រប នៅរាជធានីភ្នំពេញ ដែលក្រុមគ្រួសារ និង មេធាវីរបស់ពួកគាត់អាចជួបប្រសើរបានជាងនេះ។ អនីតិជនគួរត្រូវបានផ្ទេរជាបន្ទាន់មកមណ្ឌលឃុំខ្លួនបណ្តោះអាសន្នណាដែលមានសម្ភារៈសម្រាប់អនីតិជន។ ខ្ញុំសូមថ្កោលទោសចំពោះការឃុំខ្លួនមិនឲ្យមានការចូលជួបរបស់អ្នកទាំង២៣ នាក់ជាច្រើនថ្ងៃ ហើយសូមជំរុញឲ្យអាជ្ញាធរទប់ស្កាត់ការកើតឡើងនូវការរំលោភបំពានសិទ្ធិមនុស្សបែបនេះម្តងទៀត។

ចំពោះការប្រើប្រាស់កម្លាំងប្រឆាំងនឹងបាតុកម្មរបស់ជនស៊ីវិល ដែលបណ្តាលឲ្យមនុស្សយ៉ាងហោចណាស់បួននាក់ស្លាប់ដោយសារការបាញ់ប្រហារ និង របួសជាច្រើននោះ ខ្ញុំសូមអំពាវនាវឲ្យរដ្ឋាភិបាលរកកន្លែងអ្នកដែលបានបាត់ខ្លួនចាប់តាំងពីព្រឹត្តិការណ៍ទាំងនេះមក។ ខ្ញុំសូមធ្វើការបញ្ជាក់ពីការអំពាវនាវរបស់ខ្ញុំទៅរដ្ឋាភិបាលឲ្យធ្វើការធានាពីការស៊ើបអង្កេតហ្មត់ចត់ ទុកចិត្ត និងឯករាជ្យ។ ខ្ញុំឃើញថា ការស៊ើបអង្កេតកំពុងធ្វើឡើង ទៅលើអ្នកតវ៉ាដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះ ដោយមិនឃើញមានការស៊ើបអង្កេតទៅលើកងកម្លាំងសន្តិសុខទេ។ ខ្ញុំសូមផ្តល់អនុសាសន៍យ៉ាងមុតមាំថា គួរធ្វើការស៊ើបអង្កេតទៅលើអ្នកដែលចេញបញ្ជាឲ្យបាញ់ប្រហារ និង អ្នកអនុវត្តបញ្ជានោះ។ ប្រសិនបើគ្មានបញ្ហាបែបនេះទេ ត្រូវតែនាំអ្នកដែលបានប្រើអាវុធបាញ់ប្រហារនោះទៅកាត់ទោស។ ចំពោះបាតុកម្ម ឬ ការតវ៉ាណាមួយដែលកើតឡើងនាពេលអនាគត រដ្ឋាភិបាលគួរតែមានការប្រយ័ត្នប្រយែងពីកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាឲ្យបានថា ការប្រើប្រាស់កម្លាំងណាមួយ ត្រូវតែឆ្លើយតបនឹងភាពចាំបាច់ ភាពស្របច្បាប់ និង ភាពសមាមាត្រ និង ត្រូវធ្វើការពន្យល់អំពីការវិធីឆ្លើយតបទាំងនោះ។

**បម្រាមមិនឲ្យធ្វើបាតុកម្ម**

ខ្ញុំមានការកត់ថា មានការប្រកាសអំពីបម្រាមបណ្តោះអាសន្នមិនឲ្យធ្វើបាតុកម្ម។ ខ្ញុំសូមផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលឲ្យធ្វើការបញ្ជាក់ពីមូលដ្ឋានច្បាប់ និង មូលហេតុ ចំពោះបម្រាមនេះ។ ខ្ញុំសូមរំលឹកដល់រដ្ឋាភិបាលថា តាមមាត្រា ៤ នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ វិធានការទាំងឡាយណាដែលងាកចេញពីកាតព្វកិច្ចដែលមានចែងក្នុងកាតិកាសញ្ញានេះ អាចធ្វើឡើងបានតែក្នុងកម្រិតតឹងរ៉ឹងមួយដែលតម្រូវដោយស្ថានភាពចាំបាច់ ក្នុងភាពអាសន្នជាសាធារណៈប៉ុណ្ណោះ ដែលគម្រាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិ ហើយស្ថានភាពចាំបាច់ ក្នុងភាពអាសន្នជាសាធារណៈត្រូវបានប្រកាសជាផ្លូវការ។ ខ្ញុំមិនបានឃើញមានការប្រកាសជាផ្លូវការពីស្ថានភាពអាសន្នជាសាធារណៈនៃភាពធ្ងន់

ធ្ងរនេះដែលជាការគម្រាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិឡើយ។ ក្នុងករណីគ្មាមូលដ្ឋានច្បាប់ទេ បម្រាមមិនឲ្យធ្វើបាតុកម្មនេះ គួរតែដកចេញវិញ។

**យន្តការសមស្របសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមា**

ខ្ញុំមានយល់ឃើញដោយមានការបារម្ភពីយន្តការដែលមានស្រាប់សម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមា ដែលជាការឆ្លើយតបនឹងការទាមទាររបស់កម្មករ។ អាជ្ញាធរគួរតែពិចារណាក្នុងការពង្រឹងយន្តការក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា ឬ បង្កើតយន្តការថ្មី ដែលមានអាណត្តិក្នុងការពិចារណាដល់ការស្រាវជ្រាវដែលចាំបាច់សម្រាប់សេចក្តីសម្រេចដោយផ្អែកលើភស្តុតាង និង ការពនិត្យឡើងវិញជាទៀងទាត់ ជាពិសេស ឆ្លុះបញ្ចាំងសមស្របពីការប្រែប្រួលក្នុងជីវភាពរស់នៅ។ កម្រិតប្រាក់ឈ្នួលដែលចុងក្រោយមានការឯកភាពនោះ តម្រូវឲ្យមានទិន្នន័យ ការវិភាគ និង ការចូលរួម មិនមែនការបង្រ្កាបទេ។ ខ្ញុំសូមអំពាវនាវឲ្យរដ្ឋាភិបាលចចារជាមួយកម្មករ និង តំណាងរបស់គេក្នុងវិស័យកាត់ដេរដោយស្មោះត្រង់ និង ស្វែងរកជំនួយអន្តរជាតិ ដូចជាអង្គការពលកម្មអន្តរជាតិ ចំពោះការបង្កើតយន្តការក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាឲ្យបានសមស្រប។

ក្នុងឋានៈជារដ្ឋភាគីនៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ រដ្ឋាភិបាលកម្ពុជាត្រូវតែធ្វើការធានាថា ប្រាក់ឈ្នួលអប្បបរមាថ្នាក់ជាតិ ត្រូវបានកំណត់ក្នុងកម្រិតមួយគ្រប់គ្រាន់ដើម្បីឲ្យកម្មករ និង ក្រុមគ្រួសាររបស់គេរស់នៅដោយសមរម្យ ហើយផលចុងក្រោយនោះ ប្រាក់ឈ្នួលអប្បបរមាថ្នាក់ជាតិត្រូវបាត់ពិនិត្យឡើងជាតាមកាលកំណត់។

ក្នុងការជួបទំនាក់ទំនងរបស់ខ្ញុំជាមួយអ្នកពាក់ព័ន្ធស្តីពីបញ្ហាការងារ ខ្ញុំក៏មានការព្រួយបារម្ភដែលបានទទួលព័ត៌មានថា កម្មករ និង មេដឹកនាំសហជីពមួយចំនួន បានប្រឈមមុខនឹងការគម្រាមកំហែង និង បំភិតបំភ័យ ដោយសារពួកគេចូលរួមក្នុងវិស័យឧស្សាហកម្ម។ ចំពោះបញ្ហានេះ ខ្ញុំសូមអំពាវនាឲ្យរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធផ្សេងទៀត ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថា សិទ្ធិចូលជាសហជីពរបស់កម្មករទាំងអស់ក្នុងប្រទេសកម្ពុជា ត្រូវបានគោរពពេញលេញ និង អ្នកសហជីពអាចអនុវត្តសកម្មភាពរបស់គេនៅក្នុងបរិយាកាសគ្មានការបំភិតបំភ័យ និង គ្រោះថ្នាក់ដល់សន្តិសុខផ្ទាល់ខ្លួន ឬ អាយុជីវិតរបស់គេ។

**កំណែទម្រង់ប្រព័ន្ធតុលាការ ការបោះឆ្នោត និងសភា**

ខ្ញុំត្រូវបានលើកទឹកចិត្ត ដោយការបញ្ជាក់ម្តងហើយម្តងទៀត ដោយលោកនាយករដ្ឋមន្ត្រីថា ច្បាប់សំខាន់ៗទាំងបី ស្តីពីប្រព័ន្ធតុលាការនឹងត្រូវបានដាក់ប្រជុំពិភាក្សានៅក្នុងសភា នៅពេលដ៏ខ្លីខាងមុខនេះ។ ខ្ញុំនឹងរង់ចាំមើលសេចក្តីលម្អិតបន្ថែមទៀត អំពីដំណើរការកំណែទម្រង់ប្រព័ន្ធតុលាការក្នុងទ្រង់ទ្រាយធំជាងនេះ ដែលត្រូវបានបញ្ជាក់ថា បានចាប់ផ្តើមធ្វើហើយ ហើយខ្ញុំត្រូវបានលើកទឹកចិត្ត ដោយការប្រកាសប្រាប់ថា កំណែទម្រង់នេះ គឺមានច្រើនលើសពីអ្វីដែលមានបញ្ជាក់នៅក្នុងអនុសាសន៍របស់ខ្ញុំទៅទៀត។

ស្រដៀងគ្នានេះដែរ ខ្ញុំត្រូវបានលើកទឹកចិត្តដោយការប្រកាសរបស់រាជរដ្ឋាភិបាលប្រាប់ខ្ញុំថា កំណែ-ទម្រង់ការបោះឆ្នោតដ៏ទូលំទូលាយនឹងចាប់ផ្តើមធ្វើពិតប្រាកដ ដោយការរៀបចំឲ្យមានសិក្ខាសាលាមួយស្តីពីបញ្ហានេះនៅខែក្រោយ។ រដ្ឋាភិបាលបានសន្យាពន្លឿនកំណែទម្រង់ក្នុងវិស័យទាំងពីរនេះ ស្របតាមអនុសាសន៍របស់ខ្ញុំ។

ទន្ទឹមនឹងកត់ត្រាអំពីការអំពាវនាវរបស់រដ្ឋាភិបាលឲ្យគណបក្សប្រឆាំងចូលសភា ខ្ញុំយល់ឃើញថា កំណែទម្រង់សភាឲ្យបានឆាប់គឺមានលក្ខណៈសំខាន់ជាសារវ័ន ដើម្បីឲ្យគណបក្សប្រឆាំងអាចដើរតួនាទីប្រកបដោយអត្ថន័យជាគណបក្សប្រឆាំងក្នុងរដ្ឋសភា។ ខ្ញុំត្រូវបានលើកទឹកចិត្ត ដោយបើកចំហរបស់លោកនាយករដ្ឋមន្ត្រីលើចំណុចនេះ ហើយសង្ឃឹមថានឹងមើលឃើញផែនការកំណែទម្រង់ជាក់ស្តែងដែលមានការឯកភាពយល់ព្រមដោយភាគីទាំងពីរ ត្រូវបានធ្វើជាសាធារណៈនៅពេលដ៏ឆាប់ តាមដែលអាចធ្វើបាន។

### សិទ្ធិដីធ្លី

ទន្ទឹមនឹងមានការស្វាគមន៍ជាទូទៅចំពោះកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ដែលរាជរដ្ឋាភិបាលបានអនុវត្តក្រោមបទបញ្ជាលេខ០០១ ចុះខែឧសភា ឆ្នាំ២០១២ ខ្ញុំបន្តមានកង្វល់អំពីបញ្ហាតម្លាភាព គណនេយ្យភាព និងភាពអវត្តមាននៃយន្តការដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងបទបញ្ជាលេខ០០១។ ទំនាស់ដីធ្លីពុំរែងទៃទៀត រាប់ទាំង តំបន់បឹងកក់ បុរីកីឡា និងសហគមន៍ដទៃទៀត គួរតែត្រូវបានដោះស្រាយឲ្យបានឆាប់ ហើយសម្បទានដីថ្មី គួរតែត្រូវបានផ្តល់នៅពេលសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ ដែលរងផលប៉ះពាល់ត្រូវបានដោះស្រាយចប់សព្វគ្រប់ហើយតែប៉ុណ្ណោះ។

### ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ

ខ្ញុំស្វាគមន៍មតិរបស់រាជរដ្ឋាភិបាល ក្នុងការចាប់ផ្តើមធ្វើការបន្ត លើការប្តេជ្ញាចិត្តរបស់ខ្លួនរយៈពេលដ៏យូរកន្លងមក ក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្សឯករាជ្យមួយ។ ខ្ញុំដឹងថា សេចក្តីព្រាងច្បាប់មួយ ត្រូវបានដំណើរការរៀបចំនៅពេលកន្លងមក ហើយថា ការងារនេះនឹងចាប់ធ្វើបន្តទៀតនៅពេលដ៏ខ្លីខាងមុខនេះ។ ខ្ញុំគូសបញ្ជាក់ថា វានឹងជួយបន្ថែមតម្លៃទៅលើហេដ្ឋាចនាសម្ព័ន្ធសិទ្ធិមនុស្សដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ ប្រសិនជាឯករាជ្យភាពរបស់វាត្រូវបានធានា ដោយអនុលោមទាំងស្រុងតាមគោលការណ៍ទីក្រុងប៉ារីស។

### ស្ថានភាពនយោបាយ

ផលប៉ះពាល់នៃការបន្តមានភាពទ័លច្រក គឺជាកង្វល់មួយដ៏ធំចំពោះខ្ញុំ ពីព្រោះតែផលប៉ះពាល់ផ្ទាល់ដែលវា មានទៅលើការទទួលបានសិទ្ធិមនុស្សដោយប្រជាជនទាំងអស់នៅកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ ខ្ញុំបានសំដែងទស្សនៈរបស់ខ្ញុំ នៅក្នុងជំនួបប្រជុំរបស់ខ្ញុំថា ការផ្សះផ្សានយោបាយគឺជាមធ្យោបាយតែមួយគត់សម្រាប់ប្រទេសនេះ និងបានស្នើយ៉ាងទទូចដល់រាជរដ្ឋាភិបាល សូមឲ្យអនុវត្តភាពបត់បែនក្នុងការស្វែងរកដំណោះស្រាយមួយ ដើម្បីបញ្ចប់ភាពទ័លច្រកនេះ។ ម្យ៉ាងវិញទៀត នៅក្នុងការជួបប្រាស្រ័យរបស់ខ្ញុំជាមួយមេដឹកគណបក្សសង្គ្រោះជាតិ ខ្ញុំបានគូសបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការបង្ហាញពីភាពបត់បែនក្នុងការដោះស្រាយរបស់ខ្លួនជាមួយរាជរដ្ឋាភិបាលក្នុងការឈានដល់ការសម្របសម្រួលគ្នាមួយខាងនយោ-

បាយ។ ដោយបានស្តាប់ភាគីទាំងពីរ ខ្ញុំជឿថាវាគឺជាការចាំបាច់សម្រាប់មេដឹកនាំទាំងអស់ ក្នុងការជំនះភាពមិនទុកចិត្តគ្នា ហើយគួរវិលត្រឡប់វិញជាបន្ទាន់ទៅកាន់តុចរចា ដោយមិនមានការអូសបន្លាយពេលវេលាតទៅទៀត អាចជាការស្ថិតក្នុងវត្តមាននៃភាគីទីបីផងដែរ ដើម្បីធ្វើជាសាក្សី ឬជាអ្នកសម្រុះសម្រួល ប្រសិនជាអាចមានប្រយោជន៍។

នៅក្នុងជំនួបប្រជុំរបស់ខ្ញុំជាមួយមេដឹកនាំគណបក្សសង្គ្រោះជាតិ ខ្ញុំបានគូសបញ្ជាក់ផងដែរថា ការអត់ឱនឲ្យគ្នា និងភាពសុខដុមរមនានៃជាតិសាសន៍គឺមានសារៈសំខាន់ណាស់សម្រាប់អនាគតនៃលិទ្ធិប្រជាធិប-តេយ្យនៅក្នុងប្រទេស។ ខ្ញុំមានការភ្ញាក់ផ្អើលដោយភាសាប្រឆាំងនឹងជនជាតិវៀតណាម ដែលមានការចោទប្រកាន់ថា ត្រូវបានគណបក្សសង្គ្រោះជាតិប្រើប្រាស់ជាសាធារណៈ។ គេបានប្រាប់ខ្ញុំផងដែរថា នៅថ្ងៃទី៣ ខែមករា នៅកន្លែងកើតមានការប៉ះទង្គិចដោយហឹង្សាកន្លងមកនៅថ្ងៃនោះ នៅជិតផ្លូវ វេង ស្រេង មានអាគារមួយចំនួនដែលជារបស់ជាតិពន្ធុវៀតណាម ត្រូវបានបំផ្លិចបំផ្លាញ ហើយរបស់របរមួយចំនួនត្រូវបានលួចប្លន់យក។ ការផ្សព្វផ្សាយទស្សនៈ ដែលផ្អែកលើឧត្តមភាព ឬការស្អប់ខ្ពើមជាតិសាសន៍ ការញុះញង់ឲ្យមានការរើសអើងជាតិសាសន៍ ក៏ដូចជារាល់អំពើហឹង្សា ឬការញុះញង់ឲ្យមានអំពើដូចនេះប្រឆាំងនឹងជាតិសាសន៍មួយ ឬក្រុមមនុស្សដែលពណ៌សម្បុរស្បែកផ្សេងទៀត ឬដើមកំណើតជាតិ គឺជាអំពើដែលមិនមាននៅក្នុងសង្គមប្រជាធិប-តេយ្យមួយឡើយ។

ខ្ញុំបានធានាដល់ភាគីទាំងពីរថា សហគមន៍អន្តរជាតិ ត្រៀមខ្លួនជាស្រេច ដើម្បីជួយដល់ពួកគេក្នុងការឈានដល់ដំណោះស្រាយនយោបាយ។

**សេចក្តីសន្និដ្ឋាន៖**

កម្ពុជាឈរលើផ្លូវបំបែកមួយដ៏សំខាន់។ ខ្ញុំមានសុទិដ្ឋិនិយម និងមានបំណងចង់ឃើញការផ្លាស់ប្តូរមួយនៅក្នុងប្រទេសនេះ ដែលគេអាចធ្វើបាន ប្រសិនជាមានការកំណត់យកការធ្វើកំណែទម្រង់ទូលំទូលាយ និងយ៉ាងម៉ឺងម៉ាត់នូវស្ថាប័នរដ្ឋមួយចំនួន ដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ទាំងបួនរបស់ខ្ញុំ ដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ការផ្លាស់ប្តូរគឺពិតជាមិនអាចជៀសផុតនោះទេ ដើម្បីបំពេញតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋនៅក្នុងពិភពលោកមួយដែលមានសក្តានុពល។ ខ្ញុំបានទទួលការធានាដ៏វិជ្ជមាននៃកំណែ-ទម្រង់ដូចនេះ នៅក្នុងដំណើរបេសកកម្មរបស់ខ្ញុំលើកនេះ ហើយខ្ញុំនឹងរង់ចាំដោយក្តីអន្ទះសារចង់ឃើញការធានាទាំងនេះ ត្រូវបានប្រែក្លាយទៅជាសកម្មភាពអនុវត្តជាក់ស្តែង។ ការផ្លាស់ប្តូរមួយកំពុងកើតមានយ៉ាងឆាប់រហ័សនៅនៅកម្ពុជា ជាងការដែលបានរំពឹងទុក ។ បញ្ហាប្រឈមសម្រាប់ថ្នាក់ដឹកនាំនយោបាយបច្ចុប្បន្ននៅក្នុងគណបក្សនយោបាយធំៗទាំងពីរនោះគឺការប្រកាន់យកការផ្លាស់ប្តូរ និងការរិះរកមធ្យោបាយមួយ ដើម្បីគ្រប់គ្រងការផ្លាស់ប្តូរនោះក្នុងឧត្តមប្រយោជន៍របស់ប្រទេស។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងនៅទីក្រុងហ្ស៊ឺណែវ ដែលបានឧបត្ថម្ភគាំទ្រដល់ខ្ញុំ ក្នុងអំឡុងពេលបំពេញបេសកកម្មនេះ។

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបេឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូប នៃគណៈមេធាវីមីឌីលថឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ាននៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្តីអាស៊ាននៃច្បាប់អន្តរជាតិ ដោយការិយាល័យព័ត៌មាននៃសាកលវិទ្យាល័យខេមប្រីដជ៍។*

(*) សូមរកមើលរបាយការណ៍ចុងក្រោយបំផុតរបស់អ្នករាយការណ៍ពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស

(A/HRC/24/36):

http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx

សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា ៖

http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

សម្រាប់រាល់សំណើព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចបញ្ជូនមកការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិ មនុស្សប្រចាំកម្ពុជា។ សូមទាក់ទងមកលោកស្រី ប៊ូស្រា រ៉ាម៉ាន ទូរស័ព្ទលេខ (Tel: + ៨៥៥ ០១២ ៧៩០ ១៧៨ អ៊ីម៉េល *brahman@ohchr.org*) ឬ លោក **ទូច ហួន** (Tel: + ៨៥៥ ០១២ ៤៧៦ ៤៩៣ អ៊ីម៉េល *htouch@ohchr.org)* ។

សម្រាប់**ការសាកសួរព័ត៌មាន**ទាក់ទងនឹងអ្នកជំនាញការឯករាជ្យ អ.ស.ប ផ្សេងៗទៀត សូមទាក់ទង៖

**សាប៉ៀរ ស៊ីលាយ៉ា** សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន ទូរស័ព្ទលេខ (Tel: + ៤១ ២២ ៩១៧ ៩៣៨៣ អ៊ីម៉េល *xcelaya@ohchr.org)*

**សិទ្ធិមនុស្ស អ.ស.ប ៖ សូមស្វែងយល់ពីយើងតាមរយៈបណ្តាញសង្គម៖**

**ហ្វេសប៊ុក ៖ Facebook:** https://www.facebook.com/unitednationshumanrights

**ធ្វីតធ័រ ៖ Twitter:** http://twitter.com/UNrightswire

**ហ្គោហ្គល ៖ Google+** gplus.to/unitednationshumanrights

**យូធូប ៖ YouTube:** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង៖ Storify:** http://storify.com/UNrightswire